**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**KINGDOM OF CAMBODIA**

Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**

**Ministry of Commerce**

No. ០៧៤ MOC / M 2004

## ប្រកាស

## ស្តីពី

## ការបង្កើតគណៈកម្មការដឹកនាំការសិក្សារបស់អង្គការ JICA ស្តីពីការបើកទីផ្សារស្រូវអង្ករ នៅកម្ពុជា

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពី ការបង្កើតក្រសួងពាណិជ្ជកម្ម
-បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ. បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្ត ទៅរបស់ក្រសួងពាណិជ្ជកម្ម
-តាមការចាំបាច់របស់ក្រសួង

## <u>**សំរេច**</u>

<u>**ប្រការ១**</u> : បង្កើតគណៈកម្មការដឹកនាំការសិក្សារបស់អង្គការ **JICA** ស្តីពីការបើកទីផ្សារស្រូវអង្ករ នៅកម្ពុជា ដែលមានទីស្នាក់ការនៅ ទីស្តី ការក្រសួងពាណិជ្ជកម្ម និង ទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

<u>**ប្រការ២**</u> : សមាសភាពមន្ត្រីក្នុងគណៈកម្មការនេះមានដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម **សុក ស៊ីផាន់ណា** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សហប្រធាន |
| ២-ឯកឧត្តម **ចំន្ទ តុងអ៊ីវ** | រដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និង នេសាទ | សហប្រធាន |
| ៣-ឯកឧត្តម **ម៉ៅ ថូរ៉ា** | អគ្គនាយកបច្ចេកទេសក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៤-ឯកឧត្តម **គុំ សារ៉ុន** | អគ្គនាយកក្រសួងកសិកម្មរុក្ខាប្រម៉ាញ់និង នេសាទ | សមាជិក |
| ៥-លោក **ច្រាក់ នក** | ប្រធាននាយកដ្ឋានជំរុញការនាំចេញ ក្រសួងពាណិជ្ជកម្ម | សមាជិក |

| | | |
|---|---|---|
| ៦-លោក គឹត សេខ | ប្រធាននាយកដ្ឋានផែនការ-ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ ក្រសួង កសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ | សមាជិក |
| ៧-លោក ផាត់ សេខ | ប្រធាននាយកដ្ឋានកសិ-ឧស្សាហកម្ម ក្រសួង កសិកម្ម រុក្ខា រុក្ខាប្រម៉ាញ និង នេសាទ | សមាជិក |
| ៨-លោក អ៊ុន ម៉ុនថា | អនុប្រធាននាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស ក្រសួងពាណិជ្ជកម្ម | សមាជិក |

**ប្រការ៣** : គណៈកម្មការនេះមានភារកិច្ចដូចខាងក្រោម :

១-សំរបសំរួលដំណើរប្រព្រឹត្តិទៅរបស់គណៈកម្មការសិក្សា ទាក់ទងដល់ការសិក្សាស្រាវជ្រាវ ។

២-ផ្តល់យោបល់មតិលើគំរោងសិក្សានានារបស់អង្គការ JICA និងណែនាំ ។

៣-ជាដៃគូចចារកិរិតបច្ចេកទេសជាមួយក្រុមសិក្សា JICA ។

៤-បំពេញការងារដទៃទៀតដែលទាក់ទងទៅនឹងក្រុមសិក្សា JICA ។

**ប្រការ៤:** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ , អាគ្គាធិការ , អគ្គនាយកបច្ចេកទេស , នាយកខុទ្ទកាល័យ , និងសាមីខ្លួនដែលមានឈ្មោះ ត្រូវអនុវត្តន៍ប្រកាសនេះអោយមានប្រសិទ្ធ ភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៤

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម-ប្រសិទ្ធ

**ចម្លងជូន**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងសាធារណៈការ និង ដឹកជញ្ជូន
- ក្រសួងទេសចរណ៍
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ដូចប្រការ៤ " ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ